# ព្រះឥន្ទ្រក្នុងសង្គមខ្មែរស.វ.ទី៧

ព្រះឥន្ទ្រ គឺជាអាទិទេពដ៏សំខាន់មួយក្នុងព្រហ្មញ្ញសាសនា ដែលខ្មែរបានស្គាល់និងគោរពប្រណិប័តន៍យ៉ាងខ្លាំងកាលពីសម័យបុរាណ។ ទ្រង់ គឺជាស្ដេចនៃស្ថានសួគ៌ តំណាងឱ្យផ្គររន្ទះ និងជាលោកបាលប្រចាំនៅទិសខាងកើត។ ក្នុងគម្ពីរខ្លះរៀបរាប់ថា ទ្រង់តែងចូលចិត្តធ្វើសង្គ្រាម ចូលចិត្តសេពសុរា និងល្មោភកាម។ ជាទូទៅ ព្រះឥន្ទ្រ មានយានជំនិះជាសត្វដំរីដែលបានមកពីការកូរសមុទ្រទឹកដោះឈ្មោះថា "ឰរ៉ាវ៉ត", មានព្រះហស្តចំនួនបួនដែលមានកេតនភណ្ឌមួយចំនួនដូចជា វជ្រ (រន្ទះ) ស័ង្ខ ធ្នូ ព្រួញ ផ្ទៃសន្ទូច និងសំណាញ់។[១] គេស្គាល់ច្បាស់ថាទ្រង់ជាទេពនៃទឹកភ្លៀងតាមរយៈទេវកថាមួយដែលរៀបរាប់អំពីការប្រយុទ្ធជាមួយអសុរមួយមានឈ្មោះថា "វិត្រ្ត"។[២]

នៅស.វ.ទី៧ គេបានបង្ហាញវត្តមានព្រះឥន្ទ្រតាមរយៈសិលាចារឹកផង និងចម្លាក់ផង។ ក្នុងនោះ មានសិលាចារឹកមួយដែលគួរឱ្យកត់សម្គាល់ គឺសិលាចារឹកចុះបញ្ជីលេខ K.604 រកឃើញនៅក្រុមប្រាសាទយាយព័ន្ធ (S17-6) ក្នុងតំបន់ប្រាសាទសំបូរព្រៃគុក ដែលនៅក្នុងគាថាទី៣ គេបានរៀបរាប់អំពីការប្រៀបធៀបឫទ្ធានុភាពព្រះរាជា គឺព្រះបាទឦសានវរ្ម័នទី១ លើសឫទ្ធានុភាពព្រះឥន្ទ្រទៅទៀត។

"ប្រយុក្តនយមេត្រេណ          កទាចិទ៑ អវនីភុជាំ
បក្សច្ឆិទាបកត៌្ណាម៑          ពជ្រី យេន វិគេមិតះ"។

ប្រែថាៈ

"ដោយបានយកឈ្នះលើកងទ័ពក្សត្រ ដែលជាសត្រូវទាំងឡាយតាមរយៈការប្រើឧបាយកលតែមួយគត់ ព្រះរាជាទ្រង់មានឫទ្ធានុភាពអស្ចារ្យលើសទេពដែលក្នុងព្រះហស្តកាន់គ្រាប់រន្ទះទៅទៀត"។[៣]

ចំណែក ចម្លាក់អំពីព្រះឥន្ទ្រនៅស.វ.ទី៧ គេនិយមឆ្លាក់ខ្លាំងណាស់ ជាពិសេស គឺឆ្លាក់នៅលើផ្ដែរទ្វារ។ ភាគច្រើន គេច្រើនឆ្លាក់ព្រះឥន្ទ្រគង់នៅលើសត្វដំរីមានក្បាលមួយ (ខុសពីសម័យអង្គរនិយមឆ្លាក់ដំរីមានក្បាលបី) នៅចំពាក់កណ្ដាលផ្ដែរ និងច្រើនតែមានរូបទេពមរុតជិះនៅលើសេះនៅអមសងខាង (រូបលេខ១-២)។ មរុត គឺជាក្រុមទ័ពខ្យល់នៅស្ថានសួគ៌ និងស្ថិតក្រោមការ

---

[១] Rodeda 2005.

[២] Coleman 1832.

[៣] Coédès 1952; Goodall 2009.

អត្ថបទដោយៈ ម៉ង់ វ៉ាលី

គ្រប់គ្រងរបស់ព្រះឥន្ទ្រ។[៤] ម៉្លោះហើយ ការដែលគេឆ្លាក់បែបនេះ ទំនងសំដៅលើដំណើរនៃការបង្អុរទឹកភ្លៀងមកស្រោចស្រពនៅលើផែនដី ដ្បិតយើងដឹងច្បាស់ហើយថា មុននឹងមានភ្លៀងភាគច្រើនតែងតែមានខ្យល់ ផ្គររន្ទះ ដែលមរុតដើរតួនាទីជាទ័ពខ្យល់ រីឯព្រះឥន្ទ្រជាអ្នកគប់វជ្រនាំឱ្យមានស្នូរផ្គររន្ទះ និងទឹកភ្លៀងធ្លាក់មក។ ក្រៅពីឆ្លាក់អមដោយទេពមរុត ខ្លះគេឆ្លាក់ព្រះឥន្ទ្រនៅចំកណ្ដាលអមដោយរូបនាគរាជនៅសងខាង ដូចយើងជួបនៅចម្លាក់ផ្ដែរទ្វារវត្តសូភាស (រូបលេខ២៣)។ នាគ គឺជាតួអង្គទេវកថាតំណាងឱ្យទឹក ម៉្លោះហើយការដែលគេឆ្លាក់នៅអមសងខាងព្រះឥន្ទ្រដែលជាទេពតំណាងឱ្យផ្គររន្ទះនិងទឹកភ្លៀងដូចគ្នាវាមិនមានអ្វីដែលគួរឱ្យចម្លែកអ្វីឡើយ។

ក្រៅពីនេះទៀត ផ្ដែរទ្វារវត្តព្រះធាតុ ខេត្តកណ្ដាល គេឆ្លាក់រូបព្រះឥន្ទ្រគង់នៅលើដំរីឰរ័តនៅចំពាក់កណ្ដាល ហើយខាងស្ដាំមានរូបព្រាហ្មណ៍ម្នាក់លុតជង្គង់ចំពោះព្រះឥន្ទ្រ និងខាងឆ្វេងមានរូបព្រះឥសូរគង់នៅលើគោនន្ទិ (រូបលេខ២៤)។ ចម្លាក់របៀបនេះ គេមិនធ្លាប់ឃើញមាននៅប្រាសាទណាផ្សេងឡើយ ហើយយើងមិនដឹងជាក់លាក់អំពីសាច់រឿងដែលគេចង់បង្ហាញឡើយ តែលោក Lunet De Lajonquière និងលោក Henri Parmetier យល់ដូចគ្នាថាទំនងជារូបភាពបង្ហាញពីព្រះរាជពិធីថ្វាយព្រះភ្លើង។[៥] ចំណែក នៅលើផ្ដែរទ្វារខាងកើតនៃប្រាសាទយាយព័ន្ធ តួប៉ម S1 គេបានបង្ហាញចម្លាក់ព្រះឥន្ទ្រត្រឹមមួយកំណាត់ខ្លួនឡើងលើ ដោយនៅលើព្រះកាយមានតុបតែងគ្រឿងតែងកាយច្រើន ដែលនៅខាងស្ដាំមានតួអង្គហែរហមចំនួនបួនជាទេពប្រុស (មានមួយអង្គជានាគរាជ) និងខាងឆ្វេងជាទេពស្រីចំនួនពីរអង្គ (អាចមានមួយអង្គជាឥន្ទ្រានី?) (រូបលេខ២៥)។ សព្វថ្ងៃ រូបចម្លាក់ភាគច្រើននៅលើផ្ដែរនេះបានរលុបអស់ច្រើនទៅហើយ តែនៅសម័យអាណានិគម រូបនៅមានសភាពល្អនៅឡើយ ហើយលោកស្រី Mireille Bénisti អាចសម្គាល់ថាជាព្រះឥន្ទ្របានដោយសារព្រះហស្តខាងស្ដាំរបស់ទ្រង់មានកាន់វជ្រ (គ្រាប់រន្ទះ)។[៦]

ក្រៅពីចម្លាក់ដែលបានបង្ហាញទាំងអម្បាលម៉ាន មានចម្លាក់ព្រះឥន្ទ្រមួយទៀតនៅស.វ.ទី៧ ដែលគេឆ្លាក់ក្នុងទម្រង់ឈរត្រង់ពេញមួយដំហរព្រះកាយនៅលើចម្លាក់ទេពនព្វគ្រោះ ដែលគេរកឃើញនៅទួលភូមិចាស់ (តំបន់ប្រាសាទសំបូរព្រៃគុក) (រូបលេខ២៦)។ ដោយហេតុថា រូបទេពនព្វគ្រោះនៅស.វ.ទី៧ គេមិនបានបង្ហាញអំពីយានជំនិះរបស់ទេព នាំឱ្យមានការពិបាកកំណត់ថាទេពណាមួយជាព្រះឥន្ទ្រឱ្យបានច្បាស់ណាស់។ ប៉ុន្តែយ៉ាងណាក៏ទេពពីរអង្គនៅខាងចុងផ្នែកខាង

---

[៤] Wendy 1981; Chakravarty 1991-1992.

[៥] Lajonquière 1902; Parmentier 1927.

[៦] Bénisti 1977.

ឆ្វេងគេអាចសម្គាល់បានថាជាព្រះកេតុ និងរាហូ (ទេពជិះលើពពក) ដែរ ហើយចម្លាក់ទេពពីរអង្គនៅខាងចុងផ្នែកខាងស្តាំវិញទំនងជាព្រះសូរ្យ និងព្រះចន្ទ្រ ហើយទេពនៅចំកណ្តាលគេដែលរាប់ពីខាងមកលេខរៀងទីប្រាំ ក៏ទំនងជាព្រះឥន្ទ្រដែរ ប្រសិនបើយើងប្រៀបធៀបជាមួយចម្លាក់ទេពនព្វគ្រោះជាច្រើនទៀតនៅសម័យអង្គរដែលគេធ្លាប់បានរកឃើញនិងសិក្សា។[៧] ចម្លាក់ព្រះឥន្ទ្រនៅលើផ្តាំងចម្លាក់ទេពនព្វគ្រោះនេះ គេឆ្លាក់ព្រះហស្តខាងស្តាំកាន់កេតនភណ្ឌ និងខាងឆ្វេងដាក់ច្រត់ចង្កេះ ប៉ុន្តែដោយសារចម្លាក់នេះរលុបទៅហើយយើងមិនអាចមើលឃើញពីកេតនភណ្ឌនោះឱ្យប្រាកដថាជាវជ្របានឡើយ។

ជារួមមក នៅស.វ.ទី៧ ព្រះឥន្ទ្រជាអាទិទេពមួយដែលខ្មែរបានជ្រួតជ្រាបនៅក្នុងសង្គមយ៉ាងខ្លាំង ដូចបានបង្ហាញថាក្នុងសិលាចារឹកគេបានប្រៀបធៀបព្រះរាជាមានឫទ្ធានុភាពលើសព្រះឥន្ទ្រ។ ចំណែកសិល្បៈវិញ គេឃើញមានចម្លាក់ព្រះឥន្ទ្រយ៉ាងច្រើនសន្ធឹកសន្ធាប់ តែច្រើនបង្ហាញនៅលើផ្តែរទ្វារខាងកើត ដែលជាទិសប្រចាំការរបស់ព្រះឥន្ទ្រ។ សាច់រឿងដែលគេនិយមឆ្លាក់ គឺព្រះឥន្ទ្រគង់នៅលើដំរីក្បាលមួយព្រះហស្តកាន់វជ្រនៅចំពាក់កណ្តាលផ្តែរ អមដោយរូបទេពមរុតជិះលើសេះ ដែលជាដំណើរការនៃការបង្អុរភ្លៀងដើម្បីស្រោចស្រពនៅលើផែនដី៕

[៧] Chhum Menghong 2020.



រូបលេខ១៖ ចម្លាក់មរុតឆ្វាក់លើផ្តែរក្នុងតំបន់ប្រាសាទសំបូរព្រៃគុក



រូបលេខ២៖ ចម្លាក់មរុតឆ្វាក់លើផ្តែរក្នុងតំបន់ប្រាសាទសំបូរព្រៃគុក (រូបថត៖ លួន ទីយ៉ា)



រូបលេខ៣៖ ផ្តែររកឃើញនៅវត្តសូកាស ខេត្តកំពង់ចាម (រូបថត៖ កុំ រតនៈពិសិដ្ឋ)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៤៖ ផ្តែរប្រាសាទព្រះធាតុ ខេត្តកណ្តាល (សព្វថ្ងៃរក្សាទុកនៅសារមន្ទីរជាតិភ្នំពេញ)
(រូបថត៖ ជា សុជាតិ)



រូបលេខ២៥៖ ផ្តែរប្រាសាទយាយព័ន្ធ តំបន់ប្រាសាទសំបូរព្រៃគុក ខេត្តកំពង់ធំ



រូបលេខ២៦៖ ផ្ទាំងចម្លាក់ទេពនព្វគ្រោះ រកឃើញនៅទួលវត្តចាស់ (តំបន់ប្រាសាទសំបូរព្រៃគុក)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

# ឯកសារយោង

**Bénisti, M.**

1977, Recherches sur le premier art khmer, VII. 'Le problème de Sambor S.1', *Art Asiatique*, Tome 33, Paris

**Charkravarty, U.**

1991-1992, 'The Marut', *Annals of the Bhandarkar Oriental Research Institute,* Vol 72.

**Chhum Menghong**

2020, 'Nine deities panel in ancient Cambodia', *Pratu*, Volume 1, London

**Cœdès, G.**

1952, "*Inscription du Cambodge*" Tome 4, Hanoi

**Coleman, C.**

1832, '*The mythology of the Hindus with notices of various mountain and island tribes*', London

**Goodall, D.**

2019, Nobles, bureaucrats or strongmen? On the "Vassal Kings" or "Hereditary Governors" of pre-Angkorian city-states : Two Sanskrit inscriptions of Vidyavisesa, seventh- century governor of Tamandarapura (K.1235 and K.604), and an inscription of Sivadatta (K.1150), previously considered a son of Isanavarman I, *UDAYA*, No.19, Phnom Penh

**Lajonquière, L.**

1902, *Inventaire descriptive des monuments du Cambodge*, Tome I, Paris

**Parmentier, H.**

1927, *L'Art Khmer Primitif*. Paris: G. Van Oest.

**Roveda, V.**

2005, *'Image of the gods',* Bangkok

KHMER CIVILIZATION